ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០៨៥

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី ស្ថានភាពក្រោយបទឈប់បាញ់ គិតពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង១រសៀល រហូតដល់ម៉ោង៦ល្ងាច ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥នេះ **វីរយុទ្ធជនកម្ពុជា និងយោធាថៃ បានអនុវត្តបទឈប់បាញ់** ធ្វើឱ្យស្ថានភាពស្ងប់ស្ងាត់ ស្របតាមសេចក្តីប្រកាសរួម នៃកិច្ចប្រជុំពិសេសលើកទី៣ គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) នៅច្រកព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។

ជាសរុបរួម គិតចាប់ពីថ្ងៃទី៧ ខែធ្នូ មកដល់ពេលនេះ កម្ពុជារងផលប៉ះពាល់ទាំងតំបន់ស៊ីវិល ពលរដ្ឋស៊ីវិល ស្លាប់ របួស និងខូចខាតសំណង់អគារហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល ដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖ មានជនស៊ីវិលរបួសធ្ងន់១នាក់បានស្លាប់** នៅខេត្តបន្ទាយមានជ័យ។ ដូច្នេះ គិតចាប់ពីថ្ងៃទី៧ ខែធ្នូ មកដល់ម៉ោង៦ល្ងាចថ្ងៃនេះ មានពលរដ្ឋស្លាប់ចំនួន៣២នាក់ និងរបួសចំនួន៩៥នាក់។

**២-ករណីពលរដ្ឋនៅជំរំភៀសសឹក៖** សរុបគិតចាប់ពីថ្ងៃទី៧ ខែធ្នូ មកដល់ម៉ោង៦ល្ងាចថ្ងៃនេះ មានជនភៀសសឹក សរុប ៦១៨.៧០៩នាក់ ក្នុងនោះស្ត្រី ៣២២.៨៥៥នាក់ និងកុមារ១៩៤.៦២១នាក់។ ចំនួននេះបានថយចុះ ដោយសារ មានជនភៀសសឹក **២៦.០៨៣នាក់** បានចាប់ផ្តើមវិលត្រឡប់ទៅលំនៅឋាន។

**៣-ករណីខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី២៨ ខែធ្នូនេះ របាយការណ៍បឋម នៅខេត្តព្រះវិហារ មានទីតាំងផ្តល់សេវាអប់រំ៦១ ទីតាំងផ្តល់សេវាសុខាភិបាល១៤ និងទីតាំងផ្តល់សេវារដ្ឋបាលចំនួន៧នៅបន្តបិទទ្វារ ខណៈនៅខេត្តបន្ទាយមានជ័យ មានសាលារៀន៣៣០ មូលដ្ឋានសុខាភិបាល១៣ និងរដ្ឋបាលស្រុក និងឃុំមួយចំនួននៅបន្តបិទទ្វារ ឯខេត្តពាក់ព័ន្ធផ្សេងទៀត នឹងមានបញ្ជាក់ជាបន្តបន្ទាប់។ ដោយមិនរាប់បញ្ចូលទិន្នន័យខាងលើ គិតចាប់ពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុប រួមមាន ផ្ទះ១៦០ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ៥ ស្ថានីយ៍ប្រេង១ រថយន្ត៣៣គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ២ ជង្រុកស្រូវ១ និងសត្វពាហនៈ១ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុបរួមមាន សាលារៀន៧ មណ្ឌលសុខភាព២ សំណង់អគារ១៤ វត្តអារាម៥ សាលាឆទាន១ រថយន្ត១គ្រឿង ប្រាសាទបុរាណមួយចំនួន ស្ពាន៥ ផ្សារ១ ផ្លូវចំនួន៣ និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង។ ពេលនេះ អាជ្ញាធរមានសមត្ថកិច្ច បានកំពុងបន្តយកចិត្តទុកដាក់គាំពារជនភៀសសឹកគ្រប់ជំរំ ព្រមទាំងប្រមូលទិន្នន័យផលប៉ះពាល់ស៊ីវិលបន្តបន្ទាប់។ ទន្ទឹមគ្នានេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** កំពុងយកចិត្តទុកដាក់ ពិនិត្យ និងដោះស្រាយកិច្ចការអាទិភាពជាច្រើនទៀត ដើម្បីធានាការវិលមករកប្រក្រតីភាព នៃសេវាសាធារណៈជាមូលដ្ឋាននៅតាមបណ្តាក្រុង ស្រុក និងឃុំ-សង្កាត់ ជាពិសេសក្នុងខេត្តជាប់ព្រំដែនដែលបានបិទ និងផ្អាកក្នុងរយៈកាលកន្លងមក ព្រមទាំងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កលក្ខណៈជូនជនភៀសសឹកឆាប់បានវិលត្រឡប់ទៅលំនៅឋានវិញប្រកបដោយសុវត្ថិភាព។

ជាថ្មីទៀត **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានអំណរសាទរយ៉ាងក្រៃលែងចំពោះ **សេចក្តីប្រកាសរួម កិច្ចប្រជុំពិសេសលើកទី៣ សម្រេចអនុវត្តបទឈប់បាញ់។ ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពថ្លែងអំណរគុណ និងគាំទ្រយ៉ាងស្មោះស្ម័គ្រចំពោះ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានដាក់ចេញយុទ្ធសាស្ត្រការពារជាតិយ៉ាងត្រឹមត្រូវ ធ្វើឱ្យប្រជាជនកម្ពុជា ទាំងក្នុង និងក្រៅប្រទេស កាន់តែទទួលបានអារម្មណ៍កក់ក្តៅ។ ជាពិសេសប្រតិបត្តិករ គឺវីរយុទ្ធជនជួរមុខ ដែលឈរជើងយ៉ាងរឹងមាំ អង់អាចជាញជ័យ រយៈពេល**២០យប់ ២០ថ្ងៃ** ការពារអធិបតេយ្យជាតិ និងប្រជាជន។ **យើងទាំងអស់គ្នា សូមបន្ទន់កាយ សង្រួមចិត្ត គោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនពលី និងសូមចូលរួមទទួលអារម្មណ៍ឈឺចាប់ និងក្តីមោទនជាមួយក្រុមគ្រួសារ។** យើងក៏សូមជូនពរវីរយុទ្ធជន ដែលកំពុងសម្រាកនៅតាមមន្ទីរពេទ្យឆាប់បានជាសះស្បើយ។ សូមជនរួមជាតិ បន្តស្មារតីស្រឡាញ់ខ្មែរតែមួយជានិរន្តរ៍រៀងទៅ។

ថ្ងៃអាទិត្យ ៩កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥